ការសង្កេតបានបង្ហាញឲ្យឃើញថា ចាប់ពីពេលចុះបញ្ជីបេក្ខជនគណបក្សនយោបាយ មកដល់បច្ចុប្បន្ននេះ មានអំពើហឹង្សាទាក់ទិនសកម្មជនគណបក្សនយោបាយនៅខេត្តចំនួន ៣ គឺខេត្តសៀមរាប ពោធិ៍សាត់ កំពង់ចាម ក្នុងនោះអំពើឃាតកម្មចំនួន ៣ ករណី ស្លាប់មនុស្សចំនួន ៣ នាក់ ទៅលើបេក្ខជនគណបក្សនរោត្តមរណឫទ្ធិ ១ ករណី កើតឡើងនៅខេត្តពោធិ៍សាត់ ១ករណី កើតឡើងនៅខេត្តសៀមរាប ទៅលើសកម្មជនគណបក្សសមរង្ស៊ី និង១ករណីទៀត កើតឡើងនៅខេត្តកំពង់ចាម ទៅលើបេក្ខជនគណបក្សសិទ្ធិមនុស្ស ។ មានករណី ១ទៀត ដែលជាការធ្វើអត្តឃាតរបស់បេក្ខជនក្រុមប្រឹក្សាឃុំនៅខេត្តកំពង់ចាមរបស់គណបក្សសិទ្ធិមនុស្សដោយពុំដឹងមូលហេតុ ។

បើទោះបីពុំទាន់មានការសន្និដ្ឋានថា ករណីឃាតកម្មទាំងប៉ុន្មាននេះពាក់ព័ន្ធទៅនឹងឃាតកម្មនយោបាយឬយ៉ាងណាក៏ដោយ ក៏ប៉ុន្តែករណីនេះបានកើតឡើងចំពោះសកម្មជនគណបក្សនយោបាយក្នុងដំណាក់កាលនៃដំណើរការបោះឆ្នោតច្រើនខុសពីធម្មតា ។

បើសង្កេតមើលពីកំឡុងពេល ជាង ១០ ថ្ងៃនៃដំណើរការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតនេះ ជាទូទៅគណៈកម្មាធិការខុមហ្វ្រែល បានសង្កេតឃើញថា បរិយាកាស និងដំណើរការមានភាពប្រសើរជាងឆ្នាំ២០០៧ ។ ការសង្កេតពុំទាន់ឃើញមានការបង្កជាឧបសគ្គ និងហឹង្សាធ្ងន់ធ្ងរ ដែលបណ្តាលឲ្យសកម្មភាពនយោបាយរបស់គណបក្សនយោបាយនានាមិនអាចដំណើរការបាននៅមណ្ឌលឃុំសង្កាត់ ។

គណៈកម្មាធិការខុមហ្វ្រែលយល់ឃើញថាករណីហិង្សាខ្លះដែលកើតឡើងនេះ អាចជះឥទ្ធិពលទៅលើបរិយាកាសមុនការបោះឆ្នោតដែលធ្វើឲ្យប្រជាពលរដ្ឋមានការភ័យខ្លាចក្នុងការប្រើសេរីភាពបញ្ចេញមតិ និងសេរីភាពប្រមូលផ្តុំ។

ករណីកើតឡើងនៅខេត្តកោះកុង លោក ឈុត វុទ្ធី ប្រធានអង្គការការពារធនធានធម្មជាតិ និងបរិដ្ឋាន ការបាញ់សំលាប់ទៅលើកុមារី ហេង ចន្ថា អាយុ ១៤ ឆ្នាំ ដោយកងកំលាំងប្រដាប់អាវុធចំរុះ ការសំរេចឃុំខ្លួនយ៉ាងប្រញាប់ប្រញាល់ទៅលើតំណាងសហគមន៍បឹងកក់ចំនួន ១៥ នាក់ដោយ សាលាដំបូងរាជធានីភ្នំពេញ និងសកម្មភាពបាញ់បង្ក្រាបបាតុកម្មចំពោះកម្មការិនីចំនួន ៣នាក់នៅខេត្តស្វាយរៀង ដែលជាការបង្ក្រាបដោយហិង្សារបស់កងកំលាំងប្រដាប់អាវុធមកលើបាតុកម្មដោយសន្តិវិធីក្នុងប្រទេសកម្ពុជា ។

ការសង្កេតឃើញថា ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ និងសារព័ត៌មាន) ឯកជនមួយចំនួនមិនគោរព តាមបទបញ្ញា និងនីតិវិធី គោលការណ៍ ដែលចេញដោយ គ.ជ.ប ។ យោងតាមគោលការណ៍របស់គ.ជ.ប ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោតប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជនត្រូវតែធ្វើការបែងចែកឲ្យបានច្បាស់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវ មិនលំអៀង និងដោយការថ្លឹងថ្លែងឲ្យមានតុល្យភាព ។ ប្រព័ន្ធផ្សព្វផ្សាយទាំងនោះបានធ្វើការចាក់ផ្សាយបំរើឲ្យ ឬមានភាពលំអៀងទៅរកបេក្ខជន និងគណបក្សនយោបាយមួយៗយ៉ាងខ្លាំង ជាពិសេសទូរទស្សន៍ទាំងអស់បន្តឃោសនាឲ្យតែគណបក្សប្រជាជនកម្ពុជា និងទិះតៀនគណបក្សប្រកួតប្រជែងសំខាន់ៗយ៉ាងចាស់ដៃ ។

ការសង្កេតលើប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលពីថ្ងៃទី ១៦ ខែមករា ដល់ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១២ បង្ហាញថា គណបក្សប្រជាជនកម្ពុជាកាន់អំណាច នៅតែទទួលបានការផ្សព្វផ្សាយច្រើនជាងគេ ជាពិសេស តាមរយៈប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ និងផ្សព្វផ្សាយរដ្ឋ ខណៈដែលគណបក្សមិនកាន់អំណាចផ្សេងទៀតទទួលបាន ការផ្សព្វផ្សាយភាគច្រើនក្នុងប្រព័ន្ធផ្សព្វផ្សាយវិទ្យុឯករាជ្យ ។ ក្នុងរយៈពេលនេះដែរប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ទាំង ៣ ដូចជានេះ៍ ៣ៗ

ចាប់ពីថ្ងៃទី ១៦ ខែមករា ដល់ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១២ ខុមហ្វ្រែលសង្កេតឃើញថា មានការរំលោភបំពានទ្រព្យសម្បត្តិ និងធនធានមនុស្ស ឬមន្ត្រីរបស់រដ្ឋចំនួនប្រមាណជិត ៣០០ ករណី ។ បើទោះបីជាមានការថយចុះនូវការបង្ហាញតួនាទីរដ្ឋរបស់មន្ត្រីរាជការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយនៅកំឡុងពេលធ្វើសកម្មភាពគណបក្សនយោបាយក៏ដោយ ។

ក្នុងកំឡុងពេលឃោសនាបោះឆ្នោតដែលគិតពីថ្ងៃទី ១៨ ដល់ ២៥ ខែឧសភា ឆ្នាំ ២០១២ ការសង្កេតរកឃើញការប្រើប្រាស់ធនធានរបស់រដ្ឋតាមប្រព័ន្ធផ្សព្វផ្សាយមាន ២០ ករណី ដែលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កងយោធពលខេរភូមិន្ទ ចូលរួមសកម្មភាពឃោសនាបោះឆ្នោត ។ ឧទាហរណ៍ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១២ នាយឧត្តមសេនីយ៍ **ជា តារា** បើកយុទ្ធនាការឃោសនាបោះឆ្នោតនៅខេត្តឧត្តរមានជ័យ និងថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១២ អភិបាលរាជធានីភ្នំពេញ កែប ជុតិមា ចូលរួមឃោសនាបោះឆ្នោតនៅរាជធានីភ្នំពេញ ។

ខុមហ្វ្រែលសង្កេតឃើញថា បទបញ្ញា និងនីតិវិធីរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ប្រការ ៨.៧ នៃបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១២ ដែលមិនស្របតាមច្បាប់មួយចំនួនដោយបានអនុញ្ញាតសកម្មភាពគណបក្សនយោបាយរបស់មន្ត្រីរដ្ឋ[1] បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ។ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯក សណ្ឋាន ឬ/និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ ។ មន្ត្រីរបស់រដ្ឋប្រព្រឹត្តល្មើសនឹងប្រការ ៨.៧នេះ ត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ១៣១នៃច.ប.ត.រ (ច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រ) ។ ប៉ុន្តែប្រការនេះមិនត្រូវបានចែងដូចគ្នាជាមួយនឹងច្បាប់ស្តីពីគណបក្សនយោបាយ (១៩៩៧) និងច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ស្តីពីលក្ខន្តិកៈកងយោធពលខេមរភូមិន្ទ ដែលបានហាមឃាត់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ នគរបាលជាតិ និងមន្ត្រីតុលាការអនុវត្តនូវសកម្មភាពគាំទ្រគណបក្សនយោបាយណាមួយឡើយ ។

ខុមហ្វ្រែលសង្កេតឃើញថា បទបញ្ញា និងនីតិវិធីរបស់គ.ជ.ប បានបកប្រែអព្យាក្រិត្យភាពជាពីរនិយាម ឬស្តង់ដាពីរ ដែលខុសគ្នារវាងមន្ត្រីរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ធ្វើសកម្មភាពទាក់ទងទៅនឹង

[1] មន្ត្រីរដ្ឋនិយាយយោងទៅមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាល និងកងយោធពលខេរភូមិន្ទ

ការបោះឆ្នោត និងសកម្មភាពនយោបាយ ។ ពេលវេលារបស់អង្គការក្រៅរដ្ឋាភិបាល និងសមាគមក្នុងស្រុកមិនបានលើកលែងក្នុងការធ្វើសកម្មភាពនយោបាយបន្ទាប់ពីបំពេញម៉ោងការងារ ឬក្រៅភារកិច្ច ។

ធ្វើការគូសសន្លឹកឆ្នោត ដោយគូសសញ្ញាចំណាំឲ្យដឹងពីការបោះឆ្នោតឲ្យគណបក្សរបស់គេ ។ ករណីនេះ ខុមហ្វ្រែលកំពុងនិងធ្វើការស៊ើបអង្កេតលើភាពមិនប្រក្រតីទាំងនេះ ។

ក្នុងកំឡុងពេលឃោសនាបោះឆ្នោតនេះដែរ សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួយសម្របសម្រួលឲ្យគណបក្សហ្វ៊ុនស៊ិនប៉ិច និងនរោត្តមរណឫទ្ធិបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្រួបបង្រួមគ្នាទៅជាគណបក្សតែមួយនៅវិមានសន្តិភាព កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២កន្លងមក។ ទោះជាយ៉ាងនេះក្តីសម្រាប់ការបោះឆ្នោត នៅថ្ងៃទី៣ ខែមិថុនាខាងមុខនេះ គណបក្សទាំងពីរបាននឹងកំពុងចូលរួមប្រកួតប្រជែងរៀងៗខ្លួន ហើយសម្រាប់ការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ខាងមុខ ត្រូវបានសង្កេតឃើញថាគណបក្សទាំងពីរនៅមិនទាន់មានរូបមន្តរួបរួមច្បាស់លាស់នៅឡើយដែរ ហើយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មីៗនេះហាក់មិនមែនជាជំហរពិតប្រាកដរបស់គណបក្សទាំងពីរនោះឡើយ។

របាយការណ៍ចេញផ្សាយដោយគណកម្មាធិការជាតិរៀបចំការបោះឆ្នោតគិតត្រឹមថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១២ គណកម្មាធិការជាតិរៀបចំការបោះឆ្នោតបានទទួលពាក្យបណ្តឹងជិត ៦០ករណី បើប្រៀបធៀបនឹងឆ្នាំ ២០០៧ ពាក្យបណ្តឹងបានកើនឡើងនៅថ្នាក់ឃុំសង្កាត់ និងថយចុះនៅថ្នាក់ខេត្ត ។ ប៉ុន្តែបណ្តឹងទាំងនោះត្រូវបានដោះស្រាយហើយជាង ៤០ ករណី និងកំពុងដោះស្រាយជាង ១០ ករណី ។ បណ្តឹង នោះច្រើនកើតនៅថ្នាក់ឃុំសង្កាត់ ។

ចំពោះបណ្តឹងនេះដែរ ត្រូវបានគណបក្សប្រឆាំងដែលបានដាក់ពាក្យប្តឹងពុំមានការពេញចិត្តទៅលើការ សម្រេចនៃមន្ត្រីដោះស្រាយពាក្យបណ្តឹងនោះទេ ដោយចោទថាតែមន្ត្រីទាំងនោះសុទ្ធតែមកពីគណបក្សប្រជាជនកម្ពុជា ។ ដូចគ្នានេះដែរ ខុមហ្វ្រែលក៏សង្កេតឃើញថា ពាក្យបណ្តឹងទាំងនេះគ.ជ.ប ពុំបានបើកការដោះស្រាយជាសាធារណៈ ដោយធ្វើឡើងតែសាម៉ីគណបក្ស និងគ.ជ.ប ។

**គណបក្សសមរង្ស៊ី**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី ៣ នឹងឈានមកដល់ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ប៉ុន្តែលទ្ធភាពវិលត្រឡប់ចូលស្រុកវិញរបស់លោកសមរង្ស៊ីគឺគ្មាន ដូច្នេះមានន័យថាលោកមិនមានលទ្ធភាពចូលរួមក្នុងដំណើរការបោះឆ្នោតនេះទេ ហើយករណីនេះត្រូវបានមើលឃើញ ថាវានឹងប៉ះពាល់ដល់ការប្រកួតប្រជែងការបោះឆ្នោតដោយស្មើភាព ព្រោះថាមិនមានវត្តមានថ្នាក់ដឹកនាំគណបក្សដែលធំជាងគេលំដាប់ទី ២ និងម្យ៉ាងទៀតប្រព័ន្ធបោះឆ្នោតនៅកម្ពុជាបានផ្តល់អំណាច និង តួនាទីយ៉ាងសំខាន់ដល់ប្រធានគណបក្សនយោបាយ ។

ខុមហ្វ្រែលយល់ឃើញថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រខាងមុខ គួរតែមានការ ួរ សម្របសម្រួលផ្នែកនយោបាយណាមួយ ណា ថា លតមា ន

ខុមហ្វ្រែល នៅរក្សាសំណើររបស់ខ្លួន ដែលសុំឲ្យគ.ជ.ប ប្រមូលរបាយការណ៍ ពីសៀវភៅគណនីរបស់ គណបក្សនយោបាយដើម្បីត្រួតពិនិត្យ ចំណូល និងចំណាយរបស់គណបក្សក្នុងពេលយុទ្ធនាការនេះ បើសិនមិនមាន របាយការណ៍នេះ នោះវាអាចនាំឲ្យមិនមានតម្លាភាពក្នុងដំណើរការបោះឆ្នោត ។

យោងតាមលទ្ធផលចុះបញ្ជីបេក្ខជនគណបក្សនយោបាយរបស់គ.ជ.ប ចំនួនបេក្ខនារីឈរឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៣នេះ មានការកើនឡើងពី ១៦% ក្នុងឆ្នាំ ២០០២ (សរុបក្នុងចំណោម ៨ គណបក្សនយោបាយ) ទៅ ២១% ក្នុងឆ្នាំ ២០០៧ (សរុបក្នុងចំណោម ១២គណបក្សនយោបាយ) ទៅ ២៥% ក្នុង ឆ្នាំ ២០១២ (ក្នុងចំណោម ១០ គណបក្សនយោបាយ) ។

បក្សប្រជាជនកម្ពុជា នៅស្ទើរតែគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស បានរៀបចំពិធីបោះឆ្នោតស្ទង់មតិ ឬបោះឆ្នោតសាកល្បងដើម្បីរកបេក្ខជនដែលមានប្រជាប្រិយភាពដើម្បីដាក់ឲ្យឈរឈ្មោះ។ រូបភាពនេះបើយើងមើលពីខាងក្រៅឃើញថាល្អ មានដំណើរការប្រជាធិបតេយ្យក្នុងគណបក្ស ដែលគណបក្សផ្សេងទៀតគួរយកគំរូតាម ប៉ុន្តែបញ្ហានោះនៅត្រង់ថា ដំណើរការនៃការរាប់សន្លឹកឆ្នោត ការប្រកាសលទ្ធផលមិនបានធ្វើឡើងភ្លាមៗនោះទេ គឺថាគេយកទៅរាប់នៅថ្នាក់ស្រុក/ខ័ណ្ឌខេត្ត ហើយបានរៀបចំបញ្ជីបញ្ជូនមកចុះបញ្ជីបេក្ខជននៅតាមឃុំ សង្កាត់តែម្តង និងព្រមទាំងធ្វើការកំណត់ជាស្រេចនូវលេខរៀងបេក្ខជនឈរឈ្មោះទាំងនោះ។ ករណីនេះធ្វើឲ្យសមាជិកមួយចំនួនមិនអស់ចិត្ត និងមិនសប្បាយចិត្តនឹងសេចក្តីសម្រេចនេះ ព្រោះថាការដាក់បេក្ខជនមួយចំនួនគឺធ្វើតាមបក្សពួក ដែលមិនធ្វើតាមលទ្ធផលនៃការបោះឆ្នោត។

ចំពោះគណបក្សសមរង្ស៊ីវិញបេក្ខជនឈរឈ្មោះត្រូវបានស្នើដោយគណបក្សថ្នាក់ឃុំ សង្កាត់ ឬផ្អែកលើការ ស្ម័គ្រចិត្តរបស់បេក្ខជន ដោយឆ្លងកាត់ការប្រជុំពិភាក្សា និងសម្រេចពីក្រុមការងារគណបក្សថ្នាក់ក្រុង ស្រុក ខណ្ឌ និង រាជធានីខេត្ត។ បើពិនិត្យមើលនីតិវិធីចុងក្រោយក្នុ ីសឃើញថាប្រហាក់ប្រហែលគ្នាទៅនឹងគណបក្សប្រជាជនកម្ពុជាដែរ ដោយគណបក្សថ្នាក់រាជធានីខេត្ត ជាអ្នកពិនិត្យសំរេចក្នុងការរៀបចំបញ្ជីបេក្ខជន និងកំណត់លំដាប់លេខរៀ

បេក្ខ រឈ្មោះ និងសកម្មនមួយចំនួន ពួកគេ បានបង្ហាញការពេញចិត្ត និងយល់ស្របនឹងសេចក្តីសំរេចរបស់គណបក្សថ្នាក់ខេត្ត ប៉ុន្តែពួកគេបានលើកពីការលំបាកក្នុងការស្វែ រកបេក្ខ ររឈ្មោះ ដែលមានសមត្ថភាព និ ិកា ហើយបេក្ខជនដែលបានឈរឈ្មោះមានការភ័ យខ្លាច និងទទួលការអើសអើព ីអាជ្ញាធរ។ ដោយឡែកដំណើរការជ្រើសរើសបេក្ខ របស់គណប ង ទៀត ដូចជាគណបឲ្យហ៊ុនស៊ិនប៉ិច ប ិទ្ធិមនុស្ស និងគណបក្សនរោត្តម រណឫទ្ធិ ធ្វើតាមនី ិធីប្រហាប់ប្រហែលទៅនឹងគណកប្ប ស... [illegible] ...ប្រដៀងគ្នាផងដែរ។

ប្រជុំសម្រេចដាក់ឈ្មោះបេក្ខជនមួយចំនួនផងដែ ។

បេក្ខជន ឈ្មោះ

ទោះបីជាយ៉ាងណា គណបឲ្យនយោបាយ សំខាន់ៗបានដាក់បេ

ក្ខជនរបស់ខ្ល

លំបាកយ៉ាងខ្លាំងទៅលើការបំពេញសំណុំបែបបទជាបេក្ខជន ជាពិសេសចំពោះគណបក្សតូចៗ ដែលទទួលរងនូវការលំបាកច្រើនជាងគណបក្សធំៗ និងគណបក្សដែលកាន់អំណាច។ យ៉ាងតិចណាស់ក៏មានគណបក្សប្រជាធិបតេយ្យ គណបក្សខ្មែរឈប់ក្រ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សសញ្ជាតិកម្ពុជា គណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី បានលើកឡើងនូវការលំបាកដែលពួកគេបានជួបប្រទះ ។

គណបក្សដែលបានដាក់បេក្ខជនទាំងអស់ លើកលែងគណបក្សប្រជាជនកម្ពុជា បានលើកឡើង និងសង្កេតឃើញថាសុទ្ធតែជួយបញ្ហាលំបាកក្នុងការស្វែងរកបេក្ខជនមកឈរឈ្មោះសម្រាប់គណកប្ស របស់ខ្លួន ដោយសារមូលហេតុមួយចំនួនដូចជា គណបក្សខ្លះមិនមានតំណាងរបស់ខ្លួននៅតាមមូលដ្ឋានដែលខ្លួនឈរឈ្មោះ និងព្រមទាំងមានការគំរាមកំហែងដោយសម្ងាត់ និងដោយចំហ និងការបំភិតបំភ័យពីអាជ្ញាធរមូលដ្ឋាន ដែលនាំឲ្យបេក្ខជនមួយចំនួនសុំដកឈ្មោះចេញពីបញ្ជីវិញ។ ជាក់ស្តែងនៅឃុំជ្រៃបាក់ ស្រុករលាប្អៀង ខេត្តកំពង់ឆ្នាំង គណបក្សសមរង្ស៊ីប្រចាំក្នុងឃុំនេះបានលើកឡើយថាគណបក្សខ្លួនពិបាកក្នុងការរកបេក្ខជនមកឈរឈ្មោះ ព្រោះថាបេក្ខជនទាំងនោះមានការភ័យខ្លាចមានការរើសអើងពីអាជ្ញាធរ។ រីឯនៅឃុំព្រែកកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែងវិញ បេក្ខជនគណ បក្សហ្វ៊ុនស៊ិនប៉ិច បានទទួលរកការចំអកឡកឡឺយពីសមាជិកគណបក្សប្រជាជនកម្ពុជា ដោយសារខ្លួនបានឈរឈ្មោះជាបក្ខជននេះ។ នៅក្នុងឃុំទាំងពីរខាងលើ តំណាងគណបក្សសិទ្ធិមនុស្សក៏បានលើកឡើយអំពីការលំបាកក្នុងការស្វែងរកបេក្ខជន ព្រោះមានការគំរាមកំហែង រើសអើង ទិញទឹកចិត្តពីអាជ្ញាធរ និងមានការភ័យខ្លាចក្នុងការឈរឈ្មោះហ ីយករណីនេ ័បានីណោះឡើងចំពោ ឈោក្សនរោត្តម រណឫទ្ធិផងដែរ។

នៅឃុំសូទិព្វ ស្រុកជើងព្រៃ និងឃុំតុរ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចាម គយសប បានបដិសេធ/ការសុំចុះបញ្ជី ីយ្យេិ ៈ ពោរ/ណ ុ ះ